ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ៤០/១២ - ប្រេក្ត អនទើរ
កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ម៉ារ សំបូរណោ**

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ទូន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ប្រេក្ត អនទើរ ថេកស្ទាយ ហ្វេកធើរី លីមីធីត**

អាសយដ្ឋាន ៖ ភូមិលេខ ០៤ ភូមិស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល

ទូរស័ព្ទ ៖ ០៦៧ ៩៩៩ ៨៩៥ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

១- លោក តាំង ស៊ុនហេង ប្រធានរដ្ឋបាល

២- លោក សុខ ពិសិទ្ធិ ជំនួយការរដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហព័ន្ធសហជីពមោទនភាពកម្មករខ្មែរ**

- **សហជីពមោទនភាពកម្មករខ្មែរក្រុមហ៊ុន ប្រេក្ត អនទើរ ថេកស្ទាយ**

អាសយដ្ឋាន ៖ ភូមិលេខ ៤ ភូមិស្វាយរលំ ស្រុកស្អាង ខេត្តកណ្ដាល

លេខទូរស័ព្ទ ៖ ០៩២ ៩០២ ៥៦៩ ទូរសារ ៖ គ្មាន


ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ៖ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh◈ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org◈ Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិត ៖

| | |
|---|---|
| ១- លោក នៅ ទិត្យា | ប្រធានសហព័ន្ធសហជីពមោទនភាពកម្មករខ្មែរ |
| ២- លោក ប៊ុត ម៉ារ៉ា | មន្ត្រីសហព័ន្ធសហជីពមោទនភាពកម្មករខ្មែរ |
| ៣- កញ្ញា នួន សុខណៃ | ប្រធានសហជីពមោទនភាពកម្មករខ្មែរប្រចាំក្រុមហ៊ុន |
| ៤- កញ្ញា សោ ដានី | អនុប្រធានសហជីពមោទនភាពកម្មករខ្មែរប្រចាំក្រុមហ៊ុន |
| ៥- កញ្ញា អឿន សំដា | លេខាធិការសហជីពមោទនភាពកម្មករខ្មែរប្រចាំក្រុមហ៊ុន |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- នៅពេលក្រុមហ៊ុនគ្មានការងារឱ្យកម្មករនិយោជិតធ្វើ សុំឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួលពេញ១០០% (មួយភាគរយ) និងមិនឱ្យកម្មករទៅធ្វើនៅក្រុមផ្សេង។ ក្រុមហ៊ុនមិនឯកភាព ដោយសារនៅពេលក្រុមហ៊ុនគ្មានការងារឱ្យកម្មករធ្វើ ក្រុមហ៊ុននឹងបែងចែកពួកគាត់ឱ្យជួយធ្វើការក្រុមផ្សេង បើមិនអញ្ជឹងទេឱ្យពួកគាត់ឈប់សម្រាក ដោយផ្តល់ប្រាក់ឈ្នួលគោល៥០%។

២- សុំឱ្យក្រុមហ៊ុនចេញតម្លៃឡូតិ៍នៅពេលកម្មករធ្វើឡូតិ៍បានមួយឡូតិ៍ទៅពីរឡូតិ៍ និងតម្លើងតម្លៃឡូតិ៍ឱ្យខ្ពស់ជាងមុន។ ភាគីក្រុមហ៊ុនមិនឯកភាព សូមអនុវត្តតាមគោលការណ៍ចាស់។

៣- សុំឱ្យក្រុមហ៊ុនសង់ទារកដ្ឋាន និងបន្ទប់បំបៅដោះកូននៅក្នុងក្រុមហ៊ុន បើក្រុមហ៊ុនពុំមានលទ្ធភាពសង់ សុំឱ្យក្រុមហ៊ុនផ្តល់ជាប្រាក់៣០ដុល្លារក្នុងមួយខែជូនកម្មការិនី។ ភាគីក្រុមហ៊ុនមិនឯកភាព សូមអនុវត្តតាមគោលការណ៍ចាស់។

៤- ក្រុមហ៊ុនពុំមានលទ្ធភាពរៀបចំឱ្យមានទឹកក្តៅ ទឹកត្រជាក់ជូនឡើយ ប៉ុន្តែក្រុមហ៊ុនរៀបចំទឹកពិសារ មានអនាម័យជូនបងប្អូនកម្មករហូប។

៥- នៅពេលកម្មករសុំច្បាប់ក្រោម៧ថ្ងៃ សុំកុំឱ្យក្រុមហ៊ុនទាយកសំបុត្រពេទ្យ និងកម្មករមានធុរៈមិនអាចមកសុំច្បាប់បាន សុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យមិត្តិភក្តិសុំជំនួស និងកម្មករចំនួន០២ថ្ងៃ បើឈប់លើសមួយថ្ងៃ សូមឱ្យក្រុមហ៊ុនយកប៊ុងទៅចារអក្សរ A ឬព្យួរការងារកម្មករនោះឡើយ។ ភាគីក្រុមហ៊ុនមិនឯកភាព សូមអនុវត្តតាមគោលការណ៍ចាស់។

៦- សុំឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួលពីកម្មករ ដែលជាសមាជិកសហជីពមោទនភាពកម្មករខ្មែរម្នាក់១០០០ រៀល ដើម្បីបង់ជូនសហព័ន្ធសហជីពមោទនភាពកម្មករខ្មែរ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩

សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុម ប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១៧២/១២ កប/កណ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១២ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១២ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក ) ។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហជីពមោទនភាពកម្មករខ្មែរ ស្តីពីការទាមទារកែលំអរលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ។ បន្ទាប់ពីទទួលបានពាក្យបណ្តឹងនេះរួចមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញដើម្បីធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១២ ដោយទទួលលទ្ធផលសះជាចំនួន០៣ចំណុច លើការទាមទារចំនួន០៦ចំណុច។ ចំណុចវិវាទមិនសះជានេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ១៧២/ ១២ ក.ប/ក.ណ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ ២០១២។

បន្ទាប់ពីបានទទួលសំណុំរឿង លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកចូលរួមសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៦ ចំណុចនេះ នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១២ វេលាម៉ោង ៨ ៖ ៣០ នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមានក្នុងថ្ងៃសវនាការ តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការផ្សះផ្សា និងបានព្យាយាមសួររកនូវព័ត៌មានផ្សេងៗបន្ថែមទៀត ដែលទាក់ទងទៅនឹងចំណុចមិនសះជាចំនួន ០៦ ចំណុចនេះ។ ជាលទ្ធផល ភាគីវិវាទទទួលបានការសះជានឹងគ្នាចំនួន ៥ ចំណុច គឺចំណុចវិវាទទី១ ទី៣ (ដកការទាមទារ) ទី៤ ទី៥ និងទី៦ (ដកការទាមទារ) ។ ដូចនេះ ចំណុចមិនសះជា ដែលនៅសល់គឺមានចំនួនតែ ១ ចំណុច គឺចំណុចវិវាទទី២។

ក្នុងសំណុំរឿងនេះ ភាគីទាំងពីរជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុដូចខាងក្រោម

**តស៊ូតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ចស៊ូតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ប្រេគ្គត អននើរ ថេកស្ដាយ សំណើសុំផ្ទេរសិទ្ធិជូនលោក តាំង ស៊ុនហេង និងលោក សុខ ពិសិទ្ធិ ដើម្បីដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១២។

២- លក្ខន្តិកៈក្រុមហ៊ុន ប្រេគ្គត អននើរ ។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ចុះបញ្ជីកាលេខ ០៤២ សកបយ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១។

៤- តារាងប្រាក់ឈ្នួលប្រចាំខែធ្នូ ឆ្នាំ២០១១ និងខែមករា និងខែកុម្ភៈ ឆ្នាំ២០១២។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- វិញ្ញាបនប័ត្រចុះបញ្ជីកាសហជីពមោទនភាពកម្មករខ្មែរក្រុមហ៊ុន ប្រេគ្គត អននើរ ថេកស្ដាយ ចុះបញ្ជីកា លេខ ២៣៩៣ កប/វក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២។

២- លក្ខន្តិកៈសហជីពមោទនភាពកម្មករខ្មែរក្រុមហ៊ុន ប្រេគ្គត អននើរ ថេកស្ដាយ ចុះបញ្ជីកា លេខ ២៣៩៣ កប/វក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ប្រេគ្គត អននើរ ថេកស្ដាយ លេខ ១៧២ /១២ កប/កណ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១២ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ប្រេគ្គត អននើរ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១២។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ២២៤ កប/អក/វក/លកអ. ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១២ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ២២៥ កប/អក/វក/លកអ. ចុះថ្ងៃទី២៨ ខែ កុម្ភៈ ឆ្នាំ២០១២ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្ដាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ៖

- ក្រុមហ៊ុន ហ្គ្រេត អននើរ គឺជាក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ មានជួលកម្មករនិយោជិតសរុបចំនួន ១៩៥០ នាក់។
- សហជីពមោទនភាពកម្មករខ្មែរប្រចាំក្រុមហ៊ុន ហ្គ្រេត អននើរ ផេកស្ពាយ គឺជាដើមបណ្ដឹងនៅក្នុងសំណុំរឿងនេះ មានសមាជិកចំនួនប្រហែល ៨០ នាក់។

**ចំណុចវិវាទទី ២ ៖ កម្មករនិយោជិតសុំឱ្យនិយោជកចេញតម្លៃឡូត៍ នៅពេលកម្មករធ្វើឡូត៍បានមួយឡូត៍ ទៅពីរឡូត៍ និងតម្លើងតម្លៃឡូត៍ឱ្យខ្ពស់ជាងមុន**

- នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតដែលទទួលបានប្រាក់ឈ្នួល គិតតាមបរិមាណផលិតផល បានទាមទារសុំឱ្យនិយោជកចេញតម្លៃឡូត៍យ៉ាងយូរក្នុងរយៈពេលមួយសប្ដាហ៍ បន្ទាប់ពីឱ្យកម្មករនិយោជិតទាំងអស់ចាប់ផ្ដើមដេរសាកល្បង ហើយបានដកការទាមទារពីការតម្លើងតម្លៃឡូត៍ចេញពីចំណុចវិវាទនេះ។
- ការអនុវត្តនៅក្នុងក្រុមហ៊ុន គឺនិយោជកតែងតែចេញតម្លៃឡូត៍នៅថ្ងៃទី២៥ ជារៀងរាល់ចុងខែនីមួយៗ គ្រប់ប្រភេទឡូត៍ទាំងអស់ មិនថាឡូត៍ខុសគ្នា ឬយ៉ាងណានោះទេ។ ការអនុវត្តនេះ គឺមានចាប់តាំងពីពេលក្រុមហ៊ុនចាប់ផ្ដើមដំណើរការដំបូងមកម្ល៉េះ គឺក្នុងអំឡុងឆ្នាំ១៩៩៨។ ជាមធ្យម កម្មករនិយោជិតទទួលដេរស៊េរីថ្មីចំនួនពីរម៉ូតក្នុងមួយខែៗ។
- ភាគីកម្មករនិយោជិតបានលើកឡើងថា ការដែលនិយោជកចេញតម្លៃឡូត៍ឱ្យកម្មករនិយោជិតដឹង នៅថ្ងៃទី២៥ ជារៀងរាល់ខែនីមួយៗដូច្នេះ ធ្វើឱ្យកម្មករនិយោជិតបាត់បង់ឱកាសក្នុងការចរចារអំពីតម្លៃឡូត៍ មុននឹងពួកគាត់សម្រេចថា ព្រមទទួលធ្វើ ឬក៏អត់? ព្រោះពេលខ្លះតម្លៃឡូត៍ ដែលនិយោជកបានកំណត់ឱ្យនោះ គឺទាបពេក។
- នៅក្នុងក្រុមហ៊ុន មិនមានការរៀបចំក្រុមគម្រូឱ្យដេរសាកល្បង ដើម្បីឱ្យនិយោជកកំណត់តម្លៃឡូត៍នោះទេ។
- ភាគីនិយោជកពុំបានឯកភាពទៅនឹងការទាមទារទេ ដោយលើកហេតុផលថា ការដេរសាកល្បងដោយកម្មករនិយោជិតទាំងអស់ក្នុងរយៈពេលមួយសប្ដាហ៍ ពុំអាចធ្វើឱ្យនិយោជកដឹងពីលទ្ធភាព ឬសមត្ថភាពពិតប្រាកដថាតើកម្មករនិយោជិតអាចដេរបានក្នុងកម្រិតណា និងដើម្បីកំណត់ឱ្យដឹងអំពីតម្លៃឡូត៍សមរម្យនោះទេ។ ទាក់ទងទៅនឹងការកំណត់តម្លៃឡូត៍ នៅរៀងរាល់ថ្ងៃទី២៥ នេះ គឺបានអនុវត្តយូរមកហើយ ហើយវាគឺជារយៈពេលដ៏សមរម្យមួយ ដែលអាចវាស់ដឹងពីសមត្ថភាពរបស់កម្មករនិយោជិតបានពិតប្រាកដ និងដើម្បីកំណត់បាននូវតម្លៃឡូត៍។ ម៉្យាងទៀត ជាទូទៅ ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដែលទទួលបានពីការដេរស៊ីបុងកន្លងមកគឺច្រើនជាងចំនួន៦១ដុល្លារអាមេរិកក្នុងមួយខែ ពោលគឺពុំដែលមានកម្មករនិយោជិតណាទទួលបានតិចជាងចំនួនប្រាក់ឈ្នួលអប្បរមាទេ។ បើក្នុងករណីកម្មករនិយោជិតណា ទទួលបានប្រាក់ឈ្នួលតិចជាងប្រាក់ឈ្នួលអប្បរមានោះ និយោជកនឹងបន្ថែមបង្គ្រប់ឱ្យស្មើនឹងប្រាក់ឈ្នួលចំនួន៦១ដុល្លារអាមេរិកក្នុង១ខែ។
- និយោជកបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតនៅរៀងរាល់ថ្ងៃទី៧នៃខែនីមួយៗ។

THE ARBITRATION COUNCIL

**ហេតុផលនៃសេចក្តីសម្រេចៈ**

ចំណុចវិវាទទី ២ ៖ កម្មករនិយោជិតសុំឱ្យនិយោជកចេញតម្លៃឡូត៍ នៅពេលកម្មករធ្វើឡូត៍បានមួយឡូត៍ទៅពីរឡូត៍ យ៉ាងយូរមួយសប្តាហ៍ បន្ទាប់ពីកម្មករនិយោជិតចាប់ផ្តើមដេរ

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើនិយោជកចាំបាច់ត្រូវជូនដំណឹងដល់កម្មករនិយោជិតឱ្យដឹងអំពីតម្លៃឡូត៍ក្នុងរយៈពេលណាមួយដែរ ឬទេ ?

មាត្រា ១១២ នៃច្បាប់ការងារចែងថា “*និយោជកត្រូវចាត់វិធានការ ដើម្បីឱ្យដំណឹងដល់កម្មករនិយោជិតឱ្យបានច្បាស់ប្រាកដ និងងាយស្រួលយល់ ៖*

*ក-អំពីល័ក្ខខ័ណ្ឌប្រាក់ឈ្នួល ដែលត្រូវអនុវត្តចំពោះកម្មករនិយោជិតទាំងនោះ មុននឹងចូលកាន់តំណែងធ្វើការ ឬនៅគ្រប់ពេលផ្លាស់ប្តូរល័ក្ខខ័ណ្ឌទាំងនេះ ។*

*ខ-អំពីប្រាក់ឈ្នួលទាំងអស់របស់កម្មករនិយោជិតសម្រាប់រយៈពេលបើកប្រាក់ម្តងៗ កាលណាប្រាក់ឈ្នួលនោះអាចមានការផ្លាស់ប្តូរ* ” ។

តាមអត្ថន័យនៃមាត្រាខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកចាំបាច់ត្រូវជូនដំណឹងដល់កម្មករនិយោជិតឱ្យដឹងច្បាស់អំពីប្រាក់ឈ្នួល ដែលពួកគាត់នឹងត្រូវទទួលបាននាពេលខាងមុខ ជាពិសេសចំពោះការកម្រិតប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដែលអាចមានការប្រែប្រួល ឬ ផ្លាស់ប្តូរ ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតដែលទទួលប្រាក់ឈ្នួលតាមបរិមាណផលិតផលអាចប្រែប្រួលទៅតាមចំនួនផលិតផល ដែលពួកគាត់បានដេរអាស្រ័យលើតម្លៃឡូត៍នីមួយៗ ។ ដូច្នេះ ផ្អែកតាមមាត្រា ១១២ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកត្រូវតែជូនដំណឹងដល់កម្មករនិយោជិតអំពីការកម្រិតប្រាក់ឈ្នួលរបស់ពួកគាត់ឱ្យបានដឹងមុនថា តើពួកគាត់យល់ព្រមទទួលធ្វើឡូត៍នោះ ឬអត់ ជាមួយនឹងតម្លៃដែលនិយោជកបានកំណត់ ដើម្បីជៀសវាងនូវការកើតមានជំលោះ ទាស់ទែងនឹងគ្នា នៅពេលក្រោយ ។

យ៉ាងណាមិញ មាត្រា ១១២ ចំណុច “ក” នៃច្បាប់ស្តីពីការងារខាងលើ មិនបានចែងច្បាស់ថា តើនិយោជកត្រូវជូនដំណឹងអំពីប្រាក់ឈ្នួលនៃតម្លៃឡូត៍នោះ ក្នុងរយៈពេលប៉ុន្មានថ្ងៃនោះឡើយ ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦២/០៤-អ៊ីស៊ីន ហេតុផលចំណុចវិវាទទី២ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានលើកឡើងថា “*តាមន័យនៃមាត្រា ១១២ ចំណុច-ក នៃច្បាប់ការងារ ដូចដែលបានលើកឡើងខាងលើ គឺមិនមានចែងជាក់លាក់ថា និយោជកត្រូវជូនដំណឹងដល់កម្មករនិយោជិតអំពីប្រាក់ឈ្នួលក្នុងមួយឡូត៍ៗ ក្នុងរយៈពេលប៉ុន្មានថ្ងៃនោះឡើយ ប៉ុន្តែចំណុច “ក” នៃច្បាប់នេះ មានន័យច្បាស់លាស់ថា និយោជកមានកាតព្វកិច្ចក្នុងការជូនដំណឹងនេះ ។ ចំពោះចំនួនថ្ងៃ ដែលនិយោជកត្រូវការដើម្បីឱ្យអាចជូនដំណឹងទៅកម្មករនិយោជិត ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវពិចារណា ដោយផ្អែកទៅលើសេចក្តីត្រូវការជាក់ស្តែងរបស់ភាគីនិយោជក* ” ។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយក្នុងសំណុំរឿងខាងលើដែរ ។

នៅក្នុងករណីនេះ និយោជកបានជូនដំណឹងស្តីពីតម្លៃឡូត៍គ្រប់ប្រភេទឡូត៍ទាំងអស់ ដល់កម្មករនិយោជិតនៅ

រៀងរាល់ថ្ងៃទី២៥ ខែនីមួយៗ ដោយសំអាងថា រយៈពេលនេះ គឺជារយៈពេលដ៏សមរម្យមួយ ដើម្បីវាស់ឱ្យដឹងពីសមត្ថភាពពិតប្រាកដរបស់កម្មករនិយោជិត។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការចេញតម្លៃឡូតិ៍នៅថ្ងៃទី២៥ ជារៀងរាល់ខែ នេះវាក្បែរទៅនឹងថ្ងៃបើកប្រាក់ឈ្នួលរបស់កម្មករនិយោជិត (ថ្ងៃបើកប្រាក់ឈ្នួល គឺនៅរៀងរាល់ថ្ងៃទី៧) ដែលវាហាក់ដូចជាផ្ទុយទៅនឹងគោលបំណងរបស់មាត្រា ១១២ ដែលតម្រូវឱ្យនិយោជកចាំបាច់ ត្រូវជូនដំណឹងដល់កម្មករនិយោជិត ឱ្យដឹងច្បាស់អំពីប្រាក់ឈ្នួល ដែលពួកគាត់នឹងត្រូវទទួលបាននាពេលខាងមុខ ជាពិសេសចំពោះការកម្រិតប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដែលអាចមានការប្រែប្រួល ឬផ្លាស់ប្តូរ ដូចជា ក្នុងករណីប្រាក់ឈ្នួលតាមបរិមាណផលិតផលជាដើម។ ទន្ទឹមនឹងនេះដែរ និយោជកអាចជ្រើសរើសកម្មករជំនាញ ដើម្បីធ្វើជាក្រុមគម្រូ ក្នុងការដេរសាកល្បងក្នុងរយៈពេលដ៏សមរម្យមួយ មុននឹងសម្រេចចេញតម្លៃឡូតិ៍ជូនកម្មករនិយោជិត។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា រយៈពេលទូទៅសម្រាប់កំណត់តម្លៃឡូតិ៍ គឺពី៣ថ្ងៃ ទៅ៧ថ្ងៃ (១សប្តាហ៍)។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ ០៥/ ០៦-ដាប់ប៊ឺល យូ អ៊ែន ឌី ហេតុផលចំណុចវិវាទទី៧ និងលេខ ៨១/០៩-វ៉ន វេច ហេតុផលចំណុចវិវាទទី១១*)។

នៅក្នុងករណីនេះ ភាគីនិយោជកបានលើកឡើងថា គាត់ត្រូវការរយៈពេលយូរ ដើម្បីអាចកំណត់បានពីតម្លៃឡូតិ៍ ប៉ុន្តែគាត់មិនបានបញ្ជាក់អំពីភាពខុសគ្នា ដែលអាចកើតមានឡើងចំពោះប្រភេទឡូតិ៍ដែលអាចខុសគ្នា ឬ ដែលអាចស្រួល ឬ ពិបាកធ្វើជាងគ្នានោះទេ។ ពោល គឺ និយោជកកម្រិតថ្ងៃចេញតម្លៃឡូតិ៍ នៅរៀងរាល់ថ្ងៃទី២៥ នេះសម្រាប់គ្រប់ប្រភេទឡូតិ៍ទាំងអស់តែម្តង។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា រយៈពេល ៧ ថ្ងៃ គឺជារយៈពេលដ៏សមស្របមួយ ដែលអាចឱ្យនិយោជកអាចមានលទ្ធភាពវាស់ស្ទង់ពីសមត្ថភាពរបស់កម្មករនិយោជិតថា តើពួកគាត់អាចដេរបានក្នុងកម្រិតណា ហើយគាត់គួរកំណត់តម្លៃឡូតិ៍ចំនួនប៉ុន្មាន។

ហេតុដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចឱ្យនិយោជកជូនដំណឹងដល់កម្មករនិយោជិតអំពីតម្លៃឡូតិ៍តាមស៊េរីនីមួយៗ បន្ទាប់ពីកម្មករនិយោជិតធ្វើបានក្នុងរយៈពេល ៧ ថ្ងៃ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ២ ៖**

បង្គាប់ឱ្យនិយោជកជូនដំណឹងដល់កម្មករនិយោជិតអំពីតម្លៃឡូតិ៍តាមស៊េរីនីមួយៗ បន្ទាប់ពីកម្មករនិយោជិតធ្វើបាន ក្នុងរយៈពេល ៧ ថ្ងៃ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍ អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។

THE ARBITRATION COUNCIL

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក:

ឈ្មោះ ៖ **ម៉ារ សំបូរណា**

ហត្ថលេខា: ----------------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត:

ឈ្មោះ ៖ **ឌួន ស៊ីផាន់**

ហត្ថលេខា: ----------------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល:

ឈ្មោះ ៖ **ប៉ែន ប៊ុនឈា**

ហត្ថលេខា: ----------------------------------------------

THE ARBITRATION COUNCIL